ដើម្បីឱ្យយើងរាល់គ្នាអាចឡើងទៅឯឋានសួគ៌បាន ព្រះអង្គស្រឡាញ់យើង ហើយបានរៀបចំផ្លូវមួយសំរាប់ទៅឋានសួគ៌ ផ្លូវនោះ គឺជាព្រះយេស៊ូវគ្រីស្ទ ។ យើងត្រូវតែទទួលព្រះគ្រីស្ទយេស៊ូវដោយសេចក្តីជំនឿ នោះយើងនឹងទទួលបានអំណោយ គឺជាសេចក្តីសង្គ្រោះ ដូច្នេះយើងរាល់គ្នាត្រូវតែជ្រើសរើស តើយើងចង់ទទួលអ្វីដែលយើងសមនឹងទទួល គឺជាឋាននរក រឺយើងចង់ទទួល <u>អំណោយដោយឥតគិតថ្លៃពីព្រះយេស៊ូវ</u> គឺជាការអត់ទោសនូវអំពើបាបរបស់យើងរាល់គ្នា សង្ឃឹមថា អ្នកនឹងជ្រើសរើសអំណោយនេះជាជាងថ្លៃឈ្នួលនៃអំពើបាប ។

# ថ្លៃឈ្នួលដែលគ្មាននរណាម្នាក់ចង់បាន



ការិយាល័យសំរាប់ទាក់ទង
ប្រអប់ប្រៃសណីយ៍២៥០៦
ភ្នំពេញ៣

ថាម៉េច? ថ្ងៃឈ្នួលដែលគ្មាននរណាម្នាក់ចង់បាន

ប្រហែលជាអ្នកគិតថា អ្នកដែលនិយាយនេះ ពិតជាមិនគ្រប់ទឹកទេដឹង គឺគ្មាននរណាម្នាក់ដែលមិនចង់បានថ្ងៃឈ្នួលជាប្រាក់ខែរបស់ខ្លួននោះទេ ហើយប្រសិនបើជាមិនចង់បានថ្ងៃឈ្នួលទេ នោះនឹងមានអ្នកផ្សេងទៀត ចាំទទួលជាមិនខាន មែនទេ

**ប៉ុន្តែ**

នេះកំពុងតែនិយាយអំពីថ្ងៃឈ្នួលផ្សេងទៀត ដូចជាយើងរាល់គ្នាទីមួយៗ បានទទួលថ្ងៃឈ្នួលជាប្រាក់ខែរបស់ខ្លួន មកពីរាល់ការងារ ដែលយើងបានធ្វើ ព្រះគម្ពីរបានប្រាប់យើងឱ្យដឹងថា ថ្ងៃមួយយើងនឹងទទួលបានថ្ងៃឈ្នួលរបស់អំពើបាប ដែលយើងបានធ្វើដែរ ថ្ងៃឈ្នួលនេះ គឺជាថ្ងៃឈ្នួលដែលគ្មាននរណាម្នាក់ចង់បានពិតមែន នៅក្នុងព្រះគម្ពីរ រ៉ូម ៦:២៣ ថា"ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់" ។ ព្រះគម្ពីរបានប្រាប់យើងអំពីសេចក្តីស្លាប់ពីរយ៉ាង សេចក្តីស្លាប់ទី១ គឺជាពេលរូបកាយស្លាប់ មនុស្សខ្លះគិតថា ក្រោយពេលគេស្លាប់ នោះគេនឹងចាប់ជាតិ កើតជាថ្មី ប៉ុន្តែព្រះគម្ពីរថា ពេលយើងស្លាប់ ព្រលឹងវិញ្ញាណរបស់យើងនឹងចេញពីរូបកាយរបស់យើង ដើម្បីឈរនៅមុខទីជំនុំជំរះនៃព្រះ ។ ព្រះគម្ពីរថា អ្នកណាដែលមានអំពើបាបក្នុងពេលឈរខាងមុខព្រះ នោះទ្រង់នឹងបោះគេចូលទៅក្នុងបឹងភ្លើង ហើយនេះជាសេចក្តីស្លាប់ទី២ ។

វិវរណៈ ២០:១២, ១៤ ថា"នោះឃើញមានមនុស្សស្លាប់ ទាំងអ្នកធំ ទាំងអ្នកតូច គេឈរនៅចំពោះព្រះ.... រួចមនុស្សស្លាប់ទាំងអស់ត្រូវជំនុំជំរះតាមអំពើ ដែលគេបានប្រព្រឹត្តរៀងខ្លួន ចំណែកសេចក្តីស្លាប់ នឹងឋានឃុំព្រលឹងមនុស្សស្លាប់ នោះត្រូវបោះទៅក្នុងបឹងភ្លើងដែរ នេះជាសេចក្តីស្លាប់ទីពីរ" ។

ដោយព្រោះយើងមានបាប យើងមិនអាចចូលក្នុងឋានសួគ៌បានទេ ឋានសួគ៌គឺជាកន្លែងដែលព្រះគង់នៅ ហើយឋានសួគ៌គឺជាកន្លែងបរិសុទ្ធ ពីព្រោះព្រះជាបរិសុទ្ធ ដូច្នេះដោយព្រោះតែមនុស្សបានធ្វើបាប យើងសមនឹងធ្លាក់ចូលទៅក្នុងឋាននរក ។ ទំនុកដំកើង ៩:១៧ ថា" ពួកមនុស្សអាក្រក់នឹងត្រូវបំបែរ ទៅឯឋានឃុំព្រលឹងមនុស្សស្លាប់វិញ" អំពើបាបទាំងអស់ត្រូវទទួលទោស ។ ហេព្រើរ ២:២ ថា" គ្រប់ទាំងអំពើរំលង នឹងសេចក្តីរឹងចចេស ក៏ត្រូវទោសចំពោះ" ។ **នេះគឺជាថ្ងៃឈ្នួល ដែលគ្មាននរណាម្នាក់ចង់បាន ។**

ដូច្នេះគឺជាដំណឹងមិនល្អ ប៉ុន្តែខ្ញុំមានដំណឹងល្អមកជាមួយដែរ សូម្បីតែយើងរាល់គ្នា បានធ្វើបាបសមនឹងទទួលទោសធ្លាក់ទៅក្នុងឋាននរកក៏ដោយ ក៏ព្រះយេស៊ូវគ្រីស្ទបានសុគតលើឈើឆ្កាង ដើម្បីសង្គ្រោះយើងរាល់គ្នាឱ្យរួចពីឋាននរក មានន័យថា ទ្រង់សុគតជំនួសបាបរបស់យើងរាល់គ្នា